01225894

លេខ: D191

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 14 / 04 / 2016
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

| | |
|---|---|
| ចំពោះមុខ ៖ | សហចៅក្រមស៊ើបអង្កេត |
| កាលបរិច្ឆេទ ៖ | ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១៦ |
| ភាសា ៖ | អង់គ្លេស [ភាសាដើម ] |
| ចំណាត់ថ្នាក់ឯកសារ ៖ | សាធារណៈ |

# សេចក្តីអំពាវនាវសុំឱ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**
អាង ឧត្តម
Michael KARNAVAS

**ការិយាល័យរដ្ឋបាល**

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

## I. បញ្ហាចោទ

១. ដើម្បីឱ្យបទល្មើសក្លាយជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លុះត្រាណាបទល្មើសដែលមានចែង នៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(" ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក") បានប្រព្រឹត្តឡើង ក្នុងនោះរួមមាន បទល្មើសដែលបាន ប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធមានគោលដៅជាចម្បងសំដៅ លើ"ប្រជាជនស៊ីវិលណាមួយ"[1]។ មានការជជែកវែកញែកជាបន្តបន្ទាប់ និងយូរយារមក ហើយអំពីបញ្ហាចោទថាតើវត្តមានរបស់ទាហាន ឬក៏យុទ្ធជនក្នុងអត្ថន័យកាន់តែទូលាយ ដែល ស្ថិតនៅក្នុងចំណោមក្រុមគោលដៅណាមួយនោះ មានឥទ្ធិពលយ៉ាងណាទៅលើការបកស្រាយ ទស្សនាទាននេះ។ បញ្ហានេះបានក្លាយជាបញ្ហាច្បាប់មួយដ៏សំខាន់នៅក្នុងបរិបទនៃការចោទ ប្រកាន់អំពីការបោសសម្អាតទាហានផ្ទៃក្នុង ឧទាហរណ៍ របបមួយធ្វើការវាយប្រហារសំដៅ លើទាហានផ្ទាល់ខ្លួននៅក្នុងកាលៈទេសៈដែលអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងករណី ដែលលក្ខខណ្ឌផ្សេងទៀតនៅដដែល។

២. អង្គជំនុំជម្រះសាលាដំបូង ដោយស្របតាមយុត្តិសាស្ត្ររបស់សាលាក្តីពិសេសផ្សេងទៀត បាន បញ្ជាក់ថា សមាជិកនៃអង្គការប្រដាប់អាវុធ ទោះបីថាបានបាត់បង់សមត្ថភាពប្រយុទ្ធក៏ដោយ ក៏មិនមែនជា "ជនស៊ីវិល" ដែរបើយោងតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[2]។ ប៉ុន្តែ គោលការណ៍នេះត្រូវបានបញ្ជាក់ថាអនុវត្តចំពោះសមាជិកកងទ័ព ឬក្រុម ប្រដាប់អាវុធផ្សេង គឺ*មិនមែនជន*ដែលជាសមាជិករបស់រដ្ឋ ឬអង្គការដែលធ្វើការវាយប្រហារ នោះទេ ឬនិយាយម្យ៉ាងទៀតថា គោលការណ៍នេះត្រូវបានបញ្ជាក់ថាអនុវត្តចំពោះសមាជិក *ខ្មាំង*។

---

[1] សំណុំរឿង ០០២ ឯកសារ E313 *សាលក្រម* ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨២។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត,* IT-96-23 & IT-96-23/1-A, សាលដីកា ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ៩១-៩២។

[2] សំណុំរឿង ០០២ ឯកសារ E313 *សាលក្រម* ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨៦។ សំណុំរឿង ០០១ ឯកសារ E188 *សាលក្រម* ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣០៤។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Tihomir Blaškić,* IT-95-14-A, សាលដីកា ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ១១៤។

៣. អ.វ.ត.ក មិនទាន់បានពិចារណាថាតើ តាមច្បាប់ទម្លាប់អន្តរជាតិដែលចូលជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ ការវាយប្រហាររបស់រដ្ឋ ឬអង្គការទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ*ផ្ទាល់ខ្លួន* អាច ឬក៏មិនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិលបើយោងតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ("បញ្ហាចោទ")។

៤. តាមលទ្ធភាពដែលខ្ញុំបានដឹង និងរហូតមកដល់ពេលនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតមិនទាន់បានដោះស្រាយបញ្ហាចោទនេះឱ្យបានច្បាស់លាស់ទេ។

៥. ហេតុនេះ ជាការសមស្របសម្រាប់ខ្ញុំ គឺត្រូវជូនដំណឹងភាគីទាំងអស់អំពីបញ្ហាច្បាប់នេះដែលខ្ញុំកំពុងពិចារណានាពេលបច្ចុប្បន្ននេះ។ ហាក់ដូចជាថា អាចមានទឡ្ហីករណ៍ថា តាំងពីដើមដំបូងមកម្ល៉េះ ការពិភាក្សាពីមុនអំពីការបកស្រាយទស្សនាទាននេះប្រហែលជាអាចមើលរំលងផ្នែកគោលការណ៍សមហេតុផលដ៏សាមញ្ញ គឺថា យុទ្ធជន និងជនស៊ីវិល អាចមានអត្ថន័យខុសគ្នាទាំងស្រុង តែក្នុងករណីដែលយើងនិយាយអំពីយុទ្ធជន និងជនស៊ីវិលរបស់ *ខ្មាំង* តែប៉ុណ្ណោះ។ ខ្ញុំបានសម្រេចរួចហើយលើបញ្ហាចម្រូងចម្រាសអំពីភាពពាក់ព័ន្ធគ្នារវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមួយនឹងជម្លោះប្រដាប់អាវុធ[3] ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ដោយទុកបញ្ហានេះមួយឡែក គេក៏អាចផ្តល់ទឡ្ហីករណ៍ថែមទៀតថា៖ ក) ហាក់ដូចជាគ្មានការជំទាស់ទេថា របបណាមួយក្នុងគ្រាមានសន្តិភាព បានព្យាយាមបោសសម្អាតកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន ដូចជា ទាហានដែលមានជាតិពន្ធុ ឬជំនឿណាមួយនោះ គឺជារបបដែលបានប្រព្រឹត្តបទល្មើសផ្សេងៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទម្លាប់អន្តរជាតិ ពីព្រោះថា លក្ខណៈសម្បត្តិជាយុទ្ធជនរបស់ជនរងគ្រោះដោយសារពួកគាត់ជាទាហាននោះ គឺមិនជាប់ពាក់ព័ន្ធទាល់តែសោះនៅក្នុងបរិបទនេះ និង ខ)គ្មានមូលហេតុត្រូវគិតផ្ទុយពីនេះទេប្រសិនបើយុទ្ធនាការបោសសម្អាតបែបនេះបានកើតឡើងនៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ឬក៏ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ។

---

[3]សំណុំរឿង ០០៣ ឯកសារ D87/2/1.7/1 *ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងភាពពាក់ព័ន្ធជាមួយនឹងជម្លោះប្រដាប់អាវុធ* ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦។

01225897



## II. សេចក្តីអំពាវនាវសុំឲ្យដាក់សារណា

៦. ការយល់ដឹងកាន់តែច្បាស់អំពីបញ្ហាចោទ គឺអាចពាក់ព័ន្ធនឹងការចោទប្រកាន់នានានៅក្នុងសំណុំរឿង ០០៣ និងការចោទប្រកាន់នានានៅក្នុងសំណុំរឿង ០០៤ ទោះក្នុងកម្រិតតិចជាងក្តី ហើយនឹងផ្តល់ប្រយោជន៍ដល់វិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិទាំងមូល។ ហេតុនេះ ខ្ញុំអញ្ជើញភាគីទាំងអស់នៅក្នុងសំណុំរឿង ០០៣ និង ០០៤ សូមដាក់សេចក្តីអង្កេតដែលខ្លួនអាចមានអំពីបញ្ហាចោទនេះ។

៧. ខ្ញុំក៏យល់ឃើញថា យោងតាមវិធានផ្ទៃក្នុង ៣៣ ជាការសមស្របគឺត្រូវអញ្ជើញបុគ្គល ឬអង្គការដែលមានគុណវុឌ្ឍិ សូមដាក់សារណាមិនមែនជាភាគី ស្តីពីបញ្ហាចោទនេះ[4]។

៨. ខ្ញុំសូមណែនាំភាគីនៅក្នុងសំណុំរឿង និងអ្នកដែលមិនមានជាភាគី ត្រូវយោងលើសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក គឺ*សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី ៧* ដែលអាចទទួលបានតាមរយៈគេហទំព័ររបស់ អ.វ.ត.ក ដើម្បីធ្វើជាការណែនាំសម្រាប់ទម្រង់នៃសារណាជាលាយលក្ខណ៍អក្សរ។ សារណានេះមិនត្រូវលើសពី ៣,០០០ ពាក្យទេ ហើយត្រូវដាក់ជាទម្រង់ភីឌីអេហ្វ ជាភាសាខ្មែរ អង់គ្លេស ឬបារាំង។

៩. នៅពេលនេះ ភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី ត្រូវដោះស្រាយបញ្ហាចោទនេះជាបញ្ហាអង្គច្បាប់ជាទូទៅ ហើយមិនត្រូវលើកឡើងពីការចោទប្រកាន់នានានៅក្នុងសំណុំរឿង ០០៣ ឬសំណុំរឿង ០០៤ ទេ។ ភាគីនៅក្នុងសំណុំរឿង អាចដាក់សារណា/សេចក្តីសន្និដ្ឋានស្តីពីករណីជាក់លាក់នានានៅក្នុងសារណាស្ពាគរ /ដីកាសន្និដ្ឋានស្ពាគររបស់ខ្លួននៅពេលដែលខ្ញុំបានសម្រេចលើអង្គច្បាប់ និងជូនដំណឹងភាគីទាំងអស់អំពីបញ្ហាបែបនេះ។

---

[4] វិធាន ៣៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក "*នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចអញ្ជើញ ឬផ្តល់ឱកាសឲ្យអង្គការ ឬបុគ្គលណាមួយប្រគល់ជូននូវសារណាជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធទៅនឹងបញ្ហាណាមួយក៏បានក្នុងនាមជាអ្នកឯកទេសអមតុលាការ។ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ដែលពាក់ព័ន្ធត្រូវកំណត់ពេលវេលាឲ្យដាក់សារណានេះ ប្រសិនបើត្រូវធ្វើ*"។

១០. ការជ្រើសរើសសារណាពីអ្នកដែលមិនមែនជាភាគី ដើម្បីដកស្រង់ជាឯកសារយោង នឹងធ្វើឡើងដោយផ្អែកលើសមត្ថភាព។

## តាមសំអាងហេតុខាងលើ ខ្ញុំ ៖

១១. **អញ្ជើញ** ភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ សូមដាក់សារណាស្តីពីបញ្ហាចោទ នៅត្រឹមថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦។

១២. **អញ្ជើញ** អ្នកសិក្សាស្រាវជ្រាវ អង្គការសិក្សាស្រាវជ្រាវ និងអង្គការផ្សេងទៀតដែលធ្វើការក្នុងវិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិ សូមដាក់សារណាជាលាយលក្ខណ៍អក្សរក្នុងនាមជាអ្នកមិនមែនជាភាគី កុំឱ្យលើសពី ៣,០០០ ពាក្យ(រាប់បញ្ចូលទាំងជើងទំព័រ)ស្តីពីបញ្ហាចោទ នៅត្រឹមថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦។ សារណាទាំងអស់ត្រូវផ្ញើតាមអ៊ីមែលទៅក្រឡាបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត តាមរយៈអាសយដ្ឋានអ៊ីមែល៖ Chhay.Chanlyda@eccc.gov.kh ហើយត្រូវភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេបផ្នែកសិក្សាស្រាវជ្រាវរបស់ម្ចាស់សារណាមិនមែនជាភាគី ដោយដាក់ជាឯកសារដាច់ដោយឡែកក្នុងទម្រង់ភីឌីអេហ្វ។

១៣. **ជូនដំណឹង** ភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ថា យោងតាមវិធានផ្ទៃក្នុង ៣៣(២) ភាគីទាំងអស់ត្រូវមានរយៈពេល ១៥ ថ្ងៃ ដើម្បីដាក់ការឆ្លើយតបរួមទៅនឹងសារណាទាំងអស់របស់អ្នកដែលមិនមែនជាភាគី។ រយៈពេល ១៥ ថ្ងៃនេះ គឺចាប់រាប់ពីពេលជូនដំណឹងអំពីចំនួនសារណាទាំងអស់ដែលបានដាក់។ សារណាទាំងអស់នឹងត្រូវជូនដំណឹងទៅភាគីទាំងអស់ក្នុងថ្ងៃតែមួយនៅពេលដែលកាលបរិច្ឆេទកំណត់សម្រាប់ដាក់សារណា បានកន្លងផុត។ ការឆ្លើយតបរួមនេះមិនត្រូវលើសពី ៣,០០០ ពាក្យទេ (រាប់បញ្ចូលទាំងជើងទំព័រ)។

១៤. **ជូនដំណឹង** ភាគីនៅក្នុងសំណុំរឿង ថា ការឆ្លើយតបទៅនឹងសារណារបស់ភាគីផ្សេងទៀតនៅក្នុងសំណុំរឿងស្តីពីបញ្ហាចោទ នឹងមិនត្រូវអនុញ្ញាតឱ្យដាក់ទេ ហើយខ្ញុំនឹងមិនទទួលយកពិចារណាលើសារណាស្តីពីករណីជាក់លាក់ណាមួយនៅពេលនេះទេ។

១៥. ស្នើ ការិយាល័យរដ្ឋបាល សូមផ្សព្វផ្សាយសេចក្តីអំពាវនាវសុំឲ្យដាក់សារណានេះនៅលើគេហទំព័ររបស់ អ.វ.ត.ក និងចាត់វិធានការណាដែលសមស្របដើម្បីផ្សព្វផ្សាយសេចក្តីអំពាវនាវនេះទៅដល់បុគ្គល និងអង្គការដែលធ្វើការក្នុងវិស័យច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

ភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦

**Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**